ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ
សាលាខេត្តព្រៃវែង
លេខ ០១៥.....៦៨៧/១១

## សេចក្តីជូនដំណឹង

### ស្តីពីការគ្រប់គ្រង និងការប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ

- បានឃើញប្រកាសអន្តរក្រសួងលេខ ១៧៥ សហវ.ពដ.ប្រក ចុះថ្ងៃទី ២២ ខែមករា ឆ្នាំ២០០២ របស់ក្រសួងមហាផ្ទៃ និង ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីអំពីការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ
- បានឃើញសេចក្តីជូនដំណឹងលេខ ០០៤ សហវ. ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ២០០២ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីអំពីការគ្រប់គ្រងនិងប្រមូលអាករសម្រាប់បំភ្លឺសាធារណៈ។

អភិបាលនៃគណៈអភិបាលខេត្តសូមជូនដំណឹងថា៖

១- អាជីវករទាំងអស់ដែលធ្វើការផ្គត់ផ្គង់(លក់ដូរ) សុរាមេរ័យ និងបារីគ្រប់ប្រភេទ គឺជាបុគ្គលជាប់អាករសម្រាប់បំភ្លឺសាធារណៈ និងទទួលខុសត្រូវប្រមូលប្រាក់អាករពីអតិថិជនរបស់ខ្លួន។

២- អាករសម្រាប់បំភ្លឺសាធារណៈត្រូវប្រមូលតាមអត្រា ៣% លើតម្លៃសុរាមេរ័យ និងបារី ដែលលក់បានក្នុងមណ្ឌលដែនដីខេត្តនីមួយៗ។

៣- អាករសម្រាប់បំភ្លឺសាធារណៈ ត្រូវបង់ប្រចាំខែយ៉ាងយឺតត្រឹមថ្ងៃទី ១០ នៃខែបន្ទាប់ នៅស្នាក់ការពន្ធដារស្រុក-ក្រុង ដែលអាជីវកម្មដ្ឋានស្ថិតនៅ។

ទទួលបាននូវសេចក្តីជូនដំណឹងនេះ អភិបាលនៃគណៈអភិបាលខេត្តមានជំនឿថា បុគ្គលជាប់អាករសម្រាប់បំភ្លឺសាធារណៈទាំងអស់នឹងបំពេញកាតព្វកិច្ចបង់អាករ បានទាន់ពេលវេលាកំណត់ជាមិនខានឡើយ។

ព្រៃវែង,ថ្ងៃទី ០១ ខែធ្នូ ឆ្នាំ២០១១
អភិបាលនៃគណៈអភិបាលខេត្ត

អ៊ុំ_សាមី

**កន្លែងទទួល៖**

- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- អគ្គនាយកដ្ឋានពន្ធដារ
- ក្រុមប្រឹក្សាខេត្តព្រៃវែង
  "គោរពជូនជ្រាប"
- សាលាស្រុក-ក្រុង
- សាខាពន្ធដារខេត្ត
- និងស្ថាប័នពាក់ព័ន្ធ
  "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ